## ឧត្តមភាពតម្រូវឱ្យមានជាសមធម៌

ចំពោះយើងភាគច្រើន គឺភាពកើនឡើងផ្នែកអរសប្បាយអំពីចំនួនស្រកចុះនៃការឆ្លងជម្ងឺ កូវីដ និង ពេលផ្តើមបើកសម្រាប់ទទួលសិស្សថ្នាក់តូចៗត្រឡប់ចូលរៀនវិញក្នុងសប្តាហ៍ក្រោយ ក៏បែរទៅជាការមានកំហឹងទៅវិញដោយមូលហេតុអំពើព្រៃផ្សៃទាក់ទងការប្រកាន់ពូជសាសន៍នៅឯទីក្រុង អាត់ឡាន់ថា ដែលបានកើតឡើងកាលពីសប្តាហ៍កន្លងមក ហើយជាបន្ទាប់មក គឺមានការបាញ់រះក្នុងផ្សារនៅឯទីក្រុង ប៊ូលឌ័រ រដ្ឋ កូឡូរ៉ាដូ ។ បន្ទាប់ទៅទៀត យើងបានរៀនដឹងថា កូនបន្ទាយយាមសម្រាប់សង្គ្រោះអ្នកហែលទឹកនៅឆ្នេរសមុទ្រ ឡុងប៊ីច ដែលមានពណ៌លាបយ៉ាងចម្រុះឆើតឆាយកាលពីឆ្នាំកន្លងមកដោយបុគ្គលិកជាអ្នកយាមឆ្នេរសមុទ្រ ដើម្បីផ្តល់ជាកិត្តិយសទៅកាន់ក្រុមមនុស្សខ្ទើយ គឺត្រូវបានដុតកំទេចនៅផ្តើមសប្តាហ៍នេះ ។ លោកចៅហ្វាយក្រុង Robert Garcia បានពោលថា គ្មានអ្វីគួរឱ្យឆ្ងល់ទេ ដោយសារភ្លើងឆេះគឺមកពីការប្រើអំពើស្អប់ទៅកាន់ក្រុមមនុស្សខ្ទើយរបស់យើង ។

ប្រទេសជាតិ និង សហគមន៍របស់យើងសមនឹងទទួលអំពើល្អជាងនេះទៅទៀត ។ នៅតាមសាលារៀនប្រចាំតំបន់របស់យើង គឺយើងកំពុងរៀបចំជាប្រព័ន្ធសម្រាប់បង្កើតលទ្ធផលកាន់តែប្រសើរ ។ សូម្បីតែមានព្រឹត្តិការណ៍តាំងពីឆ្នាំកន្លងមកក៏ដោយ ក៏ក្រសួងអប់រំ ឌីស្រ្ទីគ ឡុងប៊ីច នៅតែពង្រឹងជំហ៊រសម្រាប់ជាអ្វីមួយ ។ របាយការណ៍ទាក់ទងការត្រៀមទុកសម្រាប់រៀននៅតាមមហាវិទ្យាល័យ និង ការប្រកបអាជីព (College and Career Graduate Profile) បានបង្ហាញយ៉ាងច្បាស់លាស់លើសទៅទៀតអំពីច្បាប់តម្រូវសម្រាប់សិស្សរៀនយកថ្នាក់ មុននឹងអាចបញ្ចប់ការសិក្សាបាន ដោយបញ្ជាក់ថា សិស្ស ដែលបញ្ចប់ការសិក្សា គឺនឹងកាន់ភ្ជាប់សេចក្តីសុចរិត និង មានសមត្ថភាពគ្រប់គ្រងមកលើផ្នែកសីលធម៌ផ្ទាល់ខ្លួន ។ យើងមានការទទួលស្គាល់ថា ឧត្តមភាព គឺរាប់បញ្ចូលទាំងការជួយបម្រុងសិស្សឱ្យបានប្រកបជោគជ័យអំពីការរស់នៅក្នុងសង្គមពោរពេញដោយប្រជារាស្ត្រចម្រុះ និង ការកាន់ភ្ជាប់ជាយោបល់យល់ឃើញ និង ជំនឿខុសៗពីគ្នា ។ យើងកំពុងបង្ហាញគំរូតាមរបៀបសហការណ៍ ដែលរាប់បញ្ចូលទាំងសម្លេងនៃសិស្សកាន់តែច្រើនមកលើការគិតគូរសម្រេចអំពីការរៀបចំបន្ទប់រៀន សាលារៀន និង កម្មវិធីផ្សេងៗស្របតាមបទពិសោធន៍របស់ពួកគេ ។ ការធ្វើរបៀបនេះ គឺនឹងជួយបង្កើតជាអ្វី ដែលយើងហៅថា ក្រសួង និសិត្ស ដែលជួយសិស្សឱ្យចេះទទួលគ្រប់គ្រងមកលើការរៀនរបស់ពួកគេតាមរយៈកិច្ចការមានសារសំខាន់កាន់តែច្រើនទៅកាន់ពួកគេ ។

យើងក៏កំពុងតែប្រើគម្រោងមួយដែរសម្រាប់ទាក់ទាញចំណែកពីបុគ្គលិករបស់យើងទាំងអស់មកលើការដោះស្រាយបញ្ហាផ្សេងៗទាក់ទងផ្នែកសមធម៌ និង ការប្រើអំពីប្រកាន់យ៉ាងច្បាស់ៗ ដើម្បីឱ្យយើងដឹកនាំជាគំរូ ។ ក្នុងនាមជាវិទ្យាស្ថានសិក្សា គឺយើងកំពុងធ្វើតាមអ្វី ដែលយើងមានសមត្ថភាពខ្ពស់ - បង្ហាត់ និង ស្វែងរកមធ្យោបាយកាន់តែប្រសើរសម្រាប់ដោះស្រាយផ្នែកវប្បធម៌ ដើម្បីជួយបម្រុងសិស្សរបស់យើងអំពីការរស់នៅក្នុងសង្គមជាភាពពិត ។ កិច្ចការនេះ ជួនកាល អាចមានជាភាពពិបាកក្នុងការលើកពិគ្រោះរវាងបុគ្គលិក និង សហគមន៍របស់យើង នៅពេលយើងគិតមើលឡើងវិញអំពីសេចក្តីអនុវត្តន៍កំពុងតែមាន ប៉ុន្តែ ឡុងប៊ីច មិនមែនជាសហគមន៍សាលារៀន ដែលគេចចោលកិច្ចការទេ ដោយមូលហេតុថា វាពិបាក ។

សមធម៌ និង ឧត្តមភាព មិនមែនជាគំនិតដាច់ពីគ្នាទេ ហើយទាំង ពីរ នេះក៏ចោលគ្នាមិនបានដែរ ។ យើងមិនអាចមានមួយ និង អត់មួយបានទេ ។ យើងដឹងថា យើងអាចបំពេញកិច្ចការនេះបាន ។ យើងធ្លាប់ឃើញសិស្សរាប់ពាន់នាក់មកពីដើមកំណើតទាំងអស់ ដែលបញ្ចប់ការសិក្សា និង ក្លាយជាមនុស្សជំនាន់មុនគេក្នុងក្រុមគ្រួសារ ដែលបានទៅរៀនបន្តនៅឯមហាវិទ្យាល័យ ហើយជារឿយៗ គឺបានទទួលជាអាហារូបករណ៍យ៉ាងពេញកម្រិតសម្រាប់រៀននៅតាមមហាវិទ្យាល័យដ៏ល្បីល្បាញ ។ សិស្សភាគច្រើនចាប់ផ្តើមចូលរៀននៅតាមមហាវិទ្យាល័យ ដោយបានទទួលពិន្ទុកម្រិតមហាវិទ្យាល័យពេញមួយឆ្នាំជាស្រេច ។ នេះជាគំរូបង្ហាញការលើកទឹកចិត្ត ដែលរៀបរាប់អំពីសិស្សទទួលឈ្នះឧបសគ្គជាច្រើនចំណែកនៅក្នុងសាលារៀនរបស់យើង ។

ប៉ុន្តែ យើងមិនទាន់ប្រកាសជ័យជំនះនៅឡើយទេ ។ ដូចយើងធ្លាប់បានឃើញពីឆ្នាំកន្លងមក និង ក្នុងពេលសប្តាហ៍ថ្មីៗនេះ គឺបញ្ហាខ្វែងគំនិតក្នុងសង្គម របួស និង អសមភាព នៅតែមាន ។ សូម្បីតែយើងមានមោទនភាពចំពោះសាលារៀនរបស់យើងក៏ដោយ ក៏យើងមិនអាចគេចបានទេពីឥទ្ធិពលកាន់តែច្រើនមកពីសង្គម ។

យើងនៅតែមានភាពអរស្បាយអំពីការត្រឡប់ចូលសាលារៀនវិញ បន្ទាប់ពីបានឆ្លងកាត់គ្រារាលដាលនៃជម្ងឺ ដែលមានភាពធ្ងន់ធ្ងរជាងគេក្នុងមួយសតវត្ស ។ នៅពេលយើងចាប់ផ្តើមបើកសាលារៀនឡើងវិញ យើងនឹងនៅតែបន្តការបំពេញកិច្ចការជាច់ៗពីគ្នា ។ ប៉ុន្តែ យើងនឹងឈររួមគ្នាសម្រាប់ប្រឆាំងសត្រូវតែមួយ ដែលប្រើអំពើស្អប់ ។ សិស្សរបស់យើងនឹងតាមដានមើល ។ យើងមិនត្រូវបណ្តោយឱ្យពួកគេធ្លាក់ទឹកចិត្តទេ ។

ដោយសេចក្តីស្មោះ,

Jill

បណ្ឌិត Jill Baker, Ed. D.
អគ្គនាយកសាលារៀន